**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

លេខ៖......................អ.ជ.ប.ជ.អ.

# កំណត់មូលហេតុសង្ខេប
# សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព
# ស្តីពីការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្នាំ២០២៤

- សូមគោរព**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត
- សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គប្រជុំគណៈរដ្ឋមន្ត្រីទាំងមូលជាទីមេត្រី

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជាទីបំផុតចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានអនុញ្ញាតឱ្យដាក់បញ្ចូលសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពស្តីពីការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្នាំ២០២៤ ក្នុងរបៀបវារៈនៃកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃនេះ។ ខ្ញុំបាទសូមឆ្លៀតឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណផងដែរចំពោះឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានយកចិត្តទុកដាក់ចាត់ចែងឱ្យមានកិច្ចសហការយ៉ាងល្អជាមួយនឹងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការរៀបចំរបាយការណ៍ដ៏សំខាន់នេះ ជាពិសេស ក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានរៀបចំកិច្ចប្រជុំជំនាញបច្ចេកទេសរួមជាមួយ ក្រុមការងារបច្ចេកទេសរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចំនួនពីរលើក គឺលើកទី១ នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៥ និងលើកទី២ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ ព្រមទាំងបានលើកសំណូមពរនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២៥ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ និងបានរៀបចំកិច្ចប្រជុំអន្តរក្រសួងចុងក្រោយ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តម សុក ផេង រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពស្តីពីការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្នាំ២០២៤ មុននឹងដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃនេះ។

ខ្ញុំបាទសូមគោរពអនុញ្ញាតជម្រាបជូន**សម្តេចមហាបវរធិបតី និងគណៈរដ្ឋមន្ត្រី** មេត្តាជ្រាបអំពីខ្លឹមសារទាំងស្រុងដូចខាងក្រោម៖



អាសយដ្ឋាន៖ អគារលេខ១៦ ផ្លូវលេខ២៧១កែង១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក ទូរស័ព្ទលេខ០៧៧ ៩៣៣ ៥៥៩ និង ០៨៦ ៦៣០ ៥៦៤
Tel: (855) 77 933 559 / 86 630 564 • E-mail: info@naaa.gov.kh • Website: www.naaa.gov.kh

## ១- គោលបំណង

របាយការណ៍វឌ្ឍនភាពស្ដីពីការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្នាំ២០២៤ ត្រូវបានរៀបចំឡើងដើម្បីតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។ របាយការណ៍នេះរៀបចំឡើងក្នុងក្របខណ្ឌអនុវត្ត សម្របសម្រួល តាមដាននិងវាយតម្លៃដែលជាភារកិច្ចរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងដាក់ចេញនូវវិធានការកែតម្រូវសមស្រប។ ទន្ទឹមនឹងនេះ តាមផែនទីចង្អុលផ្លូវការងារបង្ការជាលក្ខណៈពហុវិស័យដែលមានចែងក្នុងគោលនយោបាយជាតិ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក៏ត្រូវរាយការណ៍អំពីវឌ្ឍនភាព និងបញ្ហាប្រឈមជូនគណៈរដ្ឋមន្ត្រី និងលើកសំណើកែសម្រួលផងដែរ។

## ២- ដំណើរការរៀបចំ

នៅក្នុងដំណើរការនៃការរៀបចំរបាយការណ៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានអនុវត្តទៅតាមជំហានដូចខាងក្រោម៖

១- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានស្នើសុំក្រសួង ស្ថាប័ន រាជធានី ខេត្តឱ្យផ្ញើរបាយការណ៍ដើម្បីធ្វើការរៀបចំចងក្រង។

២- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំសេចក្ដីព្រាងរបាយការណ៍ និងដាក់ឆ្លងថ្នាក់ដឹកនាំពិនិត្យនិងកែលម្អ។

៣- ក្រុមការងារអន្តរក្រសួងតាមដានការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដែលបង្កើតឡើងដោយសេចក្ដីសម្រេចលេខ ១០៩សសរ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ ពិនិត្យនិងផ្ដល់មតិបំពេញបន្ថែម កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥។

៤- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំ និងកែសម្រួលចុងក្រោយនូវសេចក្ដីព្រាងរបាយការណ៍ មុននឹងដាក់ឆ្លងគណៈរដ្ឋមន្ត្រី។

## ៣- វិធីសាស្ត្រក្នុងការរៀបចំ

របាយការណ៍ស្ដីពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឆ្នាំ២០២៤ ត្រូវបានរៀបចំចងក្រងតាមការប្រមូលរបាយការណ៍ពីក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលជាសមាជិករបស់អាជ្ញាធរប្រយុទ្ធនឹងជំងឺអេដស៍។

របាយការណ៍ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រដែលមានកំណត់សូចនាករទាក់ទងនឹងការងារ ដូចខាងក្រោម៖

១- ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

២- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រៀបចំផែនការសកម្មភាព បញ្ជ្រាបការយល់ដឹងអំពីអេដស៍ និងការមិនរើសអើងអ្នកផ្ទុកមេរោគអេដស៍ ព្រមទាំងលើកសំណើសុំថវិកាជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- ការបញ្ចូលតំណាងអ្នកផ្ទុកមេរោគអេដស៍ ប្រជាជនគន្លឹះ និងតំណាងអង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិលចូលរួមក្នុងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់។

៤- ការកំណត់ឱ្យប្រជាជនគន្លឹះទទួលសេវាប្រ៊ីព(PrEP)។

៥- ការផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស.) ឱ្យអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។

៦- ការប្រើប្រាស់ថវិកាជាតិឱ្យមានប្រសិទ្ធភាពខ្ពស់។

៧- ក្រសួងសុខាភិបាលបន្តស្វែងរកកិច្ចសហប្រតិបត្តិការជាមួយមូលដ្ឋានសុខាភិបាលឯកជន ក្នុងការផ្តល់សេវាបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ និងទទួលរបាយការណ៍ជាក់លាក់ទៀងទាត់ពីមូលដ្ឋានសុខាភិបាលឯកជន។

## ៤- ខ្លឹមសារសង្ខេបនៃសេចក្តីព្រាងរបាយការណ៍

ជាលទ្ធផលនៃការអនុវត្តគោលនយោបាយ លើគោលដៅ៩៥-៩៥-៩៥ កម្ពុជាសម្រេចបាន ៩២-១០០-៩៨ បើគិតជាចំណាត់ថ្នាក់ កម្ពុជាយើងជាប់ចំណាត់ថ្នាក់ទី១០ក្នុងពិភពលោក។ ជារួម ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបង្កើតនិងធ្វើឱ្យដំណើរការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន និងរាជធានី ខេត្តទាំងស្រុង។ ដោយឡែក ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃខេត្តចំនួន៨កំពុងដំណើរការរៀបចំ។ ខេត្តទាំងនោះរួមមាន៖ ១-កំពត ២-ស្ទឹងត្រែង ៣-ស្វាយរៀង ៤-កោះកុង ៥-ឧត្តរមានជ័យ ៦-កណ្តាល ៧-មណ្ឌលគិរី និង៨-រតនគិរី។ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក៏បានខិតខំធ្វើការបញ្ជ្រាបការយល់ដឹងអំពីមេរោគអេដស៍ និងអំពីការមិនរើសអើងអ្នកផ្ទុកមេរោគអេដស៍ផងដែរ។ រាជធានី ខេត្ត ស្ទើរតែទាំងអស់មិនទាន់ដាក់បញ្ចូលតំណាងអ្នកផ្ទុកមេរោគអេដស៍ ប្រជាជនគន្លឹះ និងសង្គមស៊ីវិលក្នុងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍របស់ខ្លួននៅឡើយ។

ដើម្បីពន្លឿនការសម្រេចគោលដៅ៩៥ទី១ និងការបង្ការលើប្រជាជនគន្លឹះ ជាពិសេសយុវវ័យ កម្ពុជាបានបង្កើនទីតាំងធ្វើតេស្តរកមេរោគអេដស៍មួយចំនួនគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងនេះ ការផ្តល់សេវាប្រ៊ីព ក៏មានកំណើន ក៏ប៉ុន្តែមិនទាន់ដល់គោលដៅដែលបានកំណត់នៅឡើយ។ ចំណុចល្អសម្រាប់កម្ពុជាគឺការដាក់ឱ្យប្រើប្រាស់ឱសថ កាបូតេក្រាវៀ ប្រភេទចាក់ ដែលចាក់១ដងមានប្រសិទ្ធភាព២ខែ(CAB-PrEP: ជាវិធីបង្ការមុនពេលប្រព្រឹត្តប្រឈម)។

ការគ្របដណ្តប់របបថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល ដល់អ្នកផ្ទុកមេរោគអេដស៍បានកើនឡើងដល់៧១%(ស្មើនឹង៥០ ៤៣៥ លើ ៧០ ៦៥៤នាក់)។ ចំណែកឯការបញ្ជ្រាបការយល់ដឹងអំពីមេរោគអេដស៍និងជំងឺអេដស៍បានធ្វើនៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត។

ទាក់ទងនឹងផ្នែកចលនាប្រភពធនធាន ដោយមានការផ្លាស់ប្តូរនយោបាយរបស់សហរដ្ឋអាមេរិក មូលនិធិសកលធ្វើការកាត់ហិរញ្ញប្បទានសម្រាប់កម្មវិធីអេដស៍ចំនួន៣ ៦៤៩ ៤៣៣ដុល្លារអាមេរិកនៅឆ្នាំ២០២៥នេះ។ យើងប៉ាន់ស្មានថា សម្រាប់ឆ្នាំ២០២៧-២០២៩ខាងមុខ មូលនិធិសកលនឹងកាត់បន្ថយហិរញ្ញប្បទានដល់កម្ពុជាក្នុងទ្រង់ទ្រាយធំ ដោយហេតុថាលទ្ធផលនៃសន្និសីទកៀរគរជំនួយលើកទី៨ នៅប្រទេសអាហ្វ្រិកខាងត្បូង មិនបានសម្រេចតាមសំណើនៅឡើយ( បាន១១.៣៤ប៊ីលានដុល្លារ លើសំណើ ១៨ប៊ីលានដុល្លារ)។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នចំនួន១៣ មិនទាន់បានទទួលថវិកាសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍នៅឡើយ។ ក្រសួង ស្ថាប័ននោះរួមមានៈ ១-ទីស្តីការគណៈរដ្ឋមន្ត្រី ២-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៣-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៤-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៥-ក្រសួងអធិការកិច្ច ៦-ក្រសួងពាណិជ្ជកម្ម ៧-ក្រសួងរ៉ែ និងថាមពល ៨-ក្រសួងធម្មការ និងសាសនា ៩-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១០-ក្រសួងព័ត៌មាន ១១-រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ១២-រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន និង១៣-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។ ក៏ប៉ុន្តែ ទោះជាពុំមានខ្ទង់ចំណាយដោយឡែកសម្រាប់ការងារអេដស៍យ៉ាងណាក៏ដោយ ក៏ក្រសួង ស្ថាប័នទាំង១៣បានខិតខំធ្វើសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍បានមួយចំនួនដែរ។ តាមពិត អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានលើកសំណួរទៅក្រសួង ស្ថាប័នអំពីថវិកាអេដស៍ ថាតើមានឬគ្មាន ដោយក្នុងរយៈពេលកន្លងមក ក្រសួង ស្ថាប័នមួយចំនួនដែលអសកម្មតែងតែយកលេសថាគ្មានថវិកា។ ជាទូទៅ គ្រប់ក្រសួង ស្ថាប័នទាំងអស់សុទ្ធតែមានខ្ទង់ចំណាយក្នុងថវិកាជាតិសម្រាប់ប្រជុំផ្សព្វផ្សាយ បើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា បេសកកម្មក្នុងស្រុកជាដើម ដើម្បីរៀបចំគណៈកម្មាធិការអេដស៍ បញ្ជ្រាបការយល់ដឹងអំពីហានិភ័យនៃមេរោគអេដស៍ និងការមិនរើសអើងជាដើមដោយមិនចាំបាច់សុំថវិកាអេដស៍ដោយឡែកផង។ ប្រសិនបើប្រធានស្ថាប័នចេញមុខផ្ទាល់ណែនាំឱ្យគណៈកម្មាធិការអេដស៍លើកផែនការសកម្មភាព និងសូចនាករច្បាស់លាស់សម្រាប់ការងារអេដស៍ជូនក្រុមការងារ ឬអង្គភាពថវិការបស់ក្រសួង ស្ថាប័ន នោះក្រសួង ស្ថាប័នទាំង១៣ខាងលើនឹងមិនមានបញ្ហាថវិកាសម្រាប់ការងារអេដស៍ឡើយ នាពេលអនាគត។ ម្យ៉ាងទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏នឹងពិនិត្យដោយការយកចិត្តទុកដាក់ខ្ពស់ក្នុងករណីដែលក្រសួង ស្ថាប័នលើកសំណើសុំថវិកាសម្រាប់ការងារអេដស៍ដោយយោងលើគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ដែលមានកំណត់ភារកិច្ចច្បាស់លាស់ក្នុងឧបសម្ព័ន្ធទី១ នៃតារាងវិធានការគោលនយោបាយ។

ដោយមានកិច្ចសហការល្អជាមួយអង្គការUNAIDS ក្រុមការងារបច្ចេកទេសរួមរវាងរាជរដ្ឋាភិបាល និងដៃគូជាម្ចាស់ជំនួយបានដំណើរការឡើងវិញ។ កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងវេទិកាអន្តរជាតិស្តីពីអេដស៍ ទាំងក្នុងក្របខ័ណ្ឌសន្និសីទពិភពលោក ទាំងក្នុងឋានៈជាសមាជិកក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីអង្គការUNAIDS (PCB UNAIDS)។ កម្ពុជាក៏ត្រូវបានជាប់ឆ្នោតជាថ្មីឱ្យបន្តអាណត្តិសមាជិកក្រុមប្រឹក្សាសម្របសម្រួលកម្មវិធីអង្គការUNAIDS សម្រាប់ឆ្នាំ២០២៦-២០២៨។ កិច្ចសហការល្អរវាងកម្ពុជាជាមួយអង្គការUNAIDS ត្រូវបានរំលេចដោយទស្សនកិច្ចរបស់លោកជំទាវ Winnie Byanyima នាយិកាប្រតិបត្តិអង្គការUNAIDS ពីថ្ងៃទី១១ដល់១៦ ខែឧសភា ឆ្នាំ២០២៥។

ការពង្រឹងប្រព័ន្ធតាមដាន វាយតម្លៃ ត្រូវការឱ្យមានការប្រមូលទិន្នន័យ និងបញ្ចូលគ្នាតែមួយ។ ចំណុចនេះនៅពុំទាន់អាចធ្វើបាននៅឡើយដោយត្រូវការកិច្ចសហការជាមួយក្រសួងពាក់ព័ន្ធ ដែលមានទិន្នន័យរៀងៗខ្លួន។

បញ្ហាប្រឈមដែលកម្ពុជាកំពុងជួបប្រទះគឺ ក្រុមយុវវ័យបុរសរួមភេទជាមួយបុរសអាយុ១៥ទៅ២៤ឆ្នាំ ពុំបានទទួលការយល់ដឹងអំពីហានិភ័យនៃមេរោគអេដស៍ និងវិធីបង្ការការពារ ដែលនាំឱ្យអត្រាឆ្លងមេរោគអេដស៍ក្នុងចំណោមក្រុមនេះមានកម្រិតខ្ពស់។ ទន្ទឹមនឹងនេះ ក៏មានបុរសរកស៊ីផ្លូវភេទកាន់តែច្រើនដែលជំរុញឱ្យមានការឆ្លងថ្មីគួរឱ្យព្រួយបារម្ភ។ ម្យ៉ាងទៀត កង្វះថវិកាផ្តល់ជូនអង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិលក្នុងការងារអេដស៍ ធ្វើឱ្យសកម្មភាពបង្ការមានការធ្លាក់ចុះ។ ការធ្លាក់ចុះសកម្មភាពបង្ការរបស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងស្រទាប់ប្រជាជនគន្លឹះ ជាកត្តាអាចឱ្យការឆ្លងមេរោគថ្មីកើនឡើង នៅពេលដែលគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់មូលដ្ឋានឃុំ សង្កាត់ មិនទាន់ដំណើរការសកម្មនៅឡើយ។ ដរាបណាប្រទេសកម្ពុជាយើងមិនទាន់ឈានដល់ដំណាក់កាលបញ្ចប់អេដស៍ ឬការឆ្លងថ្មីមិនទាន់ធ្លាក់ចុះក្រោម១នាក់ក្នុងមួយថ្ងៃ ឬក្នុងរង្វង់២៥០នាក់ក្នុងមួយឆ្នាំ មេរោគអេដស៍អាចផ្ទុះរីករាលដាល ឡើងវិញគ្រប់ពេលវេលា ប្រសិនបើយើងធ្វេសប្រហែស មិននាំគ្នាខិតខំ ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការនោះទេ។

ឆ្លៀតឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណនិងកោតសរសើរចំពោះក្រសួង ស្ថាប័នធំៗដែលបំពេញភារកិច្ចបានល្អ និងយ៉ាងសកម្មរួមចំណែកឱ្យការប្រយុទ្ធនឹងមេរោគអេដស៍របស់កម្ពុជាយើង បានទទួលជោគជ័យនៅពេលនេះ ជាអាទិ៍ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងកាកបាទក្រហមកម្ពុជា។

ទោះជាយ៉ាងណាក៏ដោយ ដោយមានការគាំទ្រដ៏រឹងមាំពី **សម្តេចធិបតី នាយករដ្ឋមន្ត្រី** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិងកំពុងខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមនានា ដើម្បីឈានទៅសម្រេចគោលដៅ៩៥-៩៥-៩៥។ ការចូលរួមពីភាគីពាក់ព័ន្ធជាពហុវិស័យ និងការផ្លាស់ប្តូរផ្នត់គំនិតមន្ត្រីអនុវត្តគោលនយោបាយមួយចំនួន ព្រមទាំងការស្វែងរកថវិកានិងអនុវត្តផែនការសកម្មភាពឱ្យបានសមស្រប អាចនឹងនាំឱ្យកម្ពុជាឈានទៅសម្រេចគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨តាមកាលកំណត់។

## ៥- សំណូមពរ

ដើម្បីបន្តបេសកកម្មឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ឱ្យមានប្រសិទ្ធភាពខ្ពស់ ខ្ញុំបាទសូមគោរពស្នើសុំ**សម្តេចធិបតី**មេត្តាផ្តល់អនុសាសន៍សំខាន់ៗដល់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ដូចខាងក្រោម៖

១- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ណែនាំ ជួយសម្រួលឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងបណ្តាញជា

ដៃគូ មន្ទីរពាក់ព័ន្ធ(ផែនការ ទេសចរណ៍ សុខាភិបាល) និងបេឡាជាតិសន្តិសុខសង្គមជំរុញប្រជាជនគន្លឹះបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ មានជាអាទិ៍ បុរសរួមភេទជាមួយបុរស(MSM) អ្នកបំប្លែងភេទ(TG) ស្ត្រីបម្រើក្នុងសេវាកម្សាន្ត(EW) មកធ្វើតេស្តរកមេរោគអេដស៍ ពិនិត្យព្យាបាលជំងឺកាមរោគ និងប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍នានា ព្រមទាំងពន្លឿនការរៀបចំចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល(ម.ស.ស.) ដល់ប្រជាជនគន្លឹះទាំងនោះ ឱ្យបានយ៉ាងឆាប់រហ័ស និងបានទូលំទូលាយ។

២- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវប្រើប្រាស់ថវិកា ៨០លានរៀល ៦០លានរៀល ៤០លានរៀល ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានវិភាជជូនជារៀងរាល់ឆ្នាំលើការងារអេដស៍ ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពខ្ពស់។

៣- អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវណែនាំរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់លើកផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងប្រើប្រាស់ថវិកាតាមសារាចរអន្តរក្រសួងលេខ០០៧សហវ.ស.រ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រង ការចាត់ចែងនិងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុកនិងមូលនិធិឃុំ សង្កាត់ ដើម្បីទទួលបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព។

៤- គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្តត្រូវជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ដើម្បីបញ្ជ្រាបការយល់ដឹងអំពីហានិភ័យមេរោគអេដស៍និងជំងឺអេដស៍ និងការមាក់ងាយ រើសអើង ដោយទាក់ទាញនិងលើកទឹកចិត្តដល់ប្រជាជនទូទៅជាពិសេសប្រជាជនគន្លឹះមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ឱ្យបានទាន់ពេលវេលា និងទូលំទូលាយ។

៥- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តស្វែងរកជំនួយនិងហិរញ្ញប្បទានសហប្រតិបត្តិការពីអន្តរជាតិ ដៃគូអភិវឌ្ឍនានា និងវិស័យឯកជន ដើម្បីគាំទ្រដល់សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព។

៦- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យលទ្ធភាពផ្តល់ថវិកាដល់ក្រសួង ស្ថាប័ន រាជធានី ខេត្តដែលបានលើកផែនការសកម្មភាព និងសូចនាករច្បាស់លាស់ ស្របតាមភារកិច្ច ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម**សម្តេចមហាបវរធិបតី** និងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ ពិនិត្យ និងសម្រេចលើសំណូមពរខាងលើដ៏ខ្ពង់ខ្ពស់បំផុត។

សូមគោរពអរគុណ និងសូមអរគុណ។